ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

Ministry of Industry, Science, Technology & Innovation

លេខ: ៦៧៦ MISTI / ២០២២

# ប្រកាស

## ស្តីពី

## នីតិវិធី និងបែបបទនៃការស្នើសុំបញ្ជាក់លក្ខណៈមាត្រាសាស្ត្រលើទំនិញវេចខ្ចប់នាំចូល

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងប្រកាសលេខ ២៧៤ MISTI/២០២០ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ ស្តីពីបទប្បញ្ញត្តិបច្ចេកទេសនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់បរិមាណ និងស្លាកសញ្ញាទំនិញផលិត និងទំនិញវេចខ្ចប់
- យោងតាមតម្រូវការការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលដៅគ្រប់គ្រងការបញ្ជាក់លក្ខណៈមាត្រាសាស្ត្រលើទំនិញវេចខ្ចប់នាំចូល នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

ប្រកាសនេះមានគោលបំណង៖

- ធានាឱ្យការធ្វើពាណិជ្ជកម្មមានភាពយុត្តិធម៌ និងត្រឹមត្រូវ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

- ជំរុញឱ្យទំនិញវេចខ្ចប់នាំចូលស្របតាមឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់
- ជានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់
- ធ្វើឱ្យមានជំនឿទុកចិត្តលើការប្រើប្រាស់ទំនិញវេចខ្ចប់នាំចូល ក្នុងសកម្មភាពពាណិជ្ជកម្ម។

**ប្រការ៣ ._**

ប្រកាសនេះមានវិសាលភាពលើបុគ្គលដែលនាំចូលទំនិញវេចខ្ចប់សម្រាប់សកម្មភាពពាណិជ្ជកម្ម ដោយអនុលោមតាមច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ ._**

កំណត់និយមន័យវាក្យស័ព្ទសំខាន់ៗប្រើប្រាស់ក្នុងប្រកាសនេះមានដូចតទៅ៖

- **ទំនិញវេចខ្ចប់** សំដៅដល់ទំនិញដែលបានរៀបចំដាក់ស្រេចបាច់ក្នុងសម្ភារៈវេចខ្ចប់តាមវិធីសាស្ត្រណាមួយ ដែលបរិមាណរបស់វាត្រូវបានកំណត់ និងបានបញ្ជាក់លើស្លាកសញ្ញាមុននឹងបញ្ចេញលក់ ហើយដែលគេមិនអាចផ្លាស់ប្តូរ ឬកែប្រែខុសពីភាពដើមឡើយ
- **ពាណិជ្ជកម្ម** សំដៅដល់ទំនាក់ទនង ឬកិច្ចសន្យា កិច្ចព្រមព្រៀងការលក់ ការទិញ យោងតាមមាត្រា១៩ នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- **អ្នកស្នើសុំ** សំដៅដល់បុគ្គលដែលចុះហត្ថលេខាលើពាក្យស្នើសុំ
- **អ្នកនាំចូល** សំដៅដល់បុគ្គលដែលបានអនុញ្ញាតឲ្យនាំចូលនូវទំនិញវេចខ្ចប់
- **បុគ្គល** សំដៅដល់នីតិបុគ្គល ឬរូបវន្តបុគ្គល
- **ពាក្យស្នើសុំ** សំដៅដល់ពាក្យស្នើបញ្ជាក់លក្ខណៈមាត្រាសាស្ត្រលើទំនិញវេចខ្ចប់នាំចូល ដែលជាសំណើផ្លូវការដោយលាយលក្ខណ៍អក្សររបស់អ្នកស្នើសុំ ដើម្បីទទួលបាននូវសិទ្ធិលើការនាំចូលទំនិញវេចខ្ចប់ដូចមានទម្រង់ដែលកំណត់ក្នុងប្រកាសនេះ
- **បញ្ជាក់លក្ខណៈមាត្រាសាស្ត្រលើទំនិញវេចខ្ចប់នាំចូល** សំដៅដល់ការបញ្ជាក់លក្ខណៈបច្ចេកទេសលើទំនិញវេចខ្ចប់នាំចូល ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលអនុលោមតាមច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- **វិញ្ញាបនបត្របញ្ជាក់លក្ខណៈមាត្រាសាស្ត្រលើទំនិញវេចខ្ចប់នាំចូល** សំដៅដល់ឯកសារគតិយុត្ត ដែលបញ្ជាក់លក្ខណៈមាត្រាសាស្ត្រលើទំនិញវេចខ្ចប់នាំចូល ដោយអនុញ្ញាតឱ្យបុគ្គលដែលនាំចូល ឬមានបំណងនាំចូលទំនិញវេចខ្ចប់ ជាលាយលក្ខណ៍អក្សរដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍
- **ឯកសារតម្រូវ** សំដៅដល់ឯកសារពាក់ព័ន្ធនានាដែលតម្រូវឱ្យមានភាពអនុលោមជាមួយលក្ខខណ្ឌដែលបានកំណត់ក្នុងប្រកាសនេះ
- **មន្ត្រីត្រួតពិនិត្យ** សំដៅដល់មន្ត្រីរាជការ ដែលបានផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌របស់មជ្ឈមណ្ឌល មាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- **នាយកដ្ឋានទទួលបន្ទុក** សំដៅដល់នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ នៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ប្រការ៥ ..**

រាល់ទំនិញវេចខ្ចប់ អាចអនុញ្ញាតឱ្យនាំចូលសម្រាប់សកម្មភាពពាណិជ្ជកម្ម ដូចមានចែងក្នុងច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា ត្រូវមានវិញ្ញាបនបត្របញ្ជាក់លក្ខណៈមាត្រាសាស្ត្រលើទំនិញវេចខ្ចប់នាំចូល ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៦ ..**

រាល់ការនាំចូលទំនិញវេចខ្ចប់ ត្រូវបំពេញបែបបទស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលមានទីតាំងនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិរៀងរាល់ម៉ោងធ្វើការ។

ឯកសារតម្រូវមាន៖

១. ពាក្យស្នើសុំ

២. សម្រង់ព័ត៌មាន ឬរូបភាពនៃគំរូទំនិញវេចខ្ចប់ ដែលត្រូវនាំចូល

៣. បញ្ជីរាយឈ្មោះទំនិញវេចខ្ចប់ ដែលត្រូវនាំចូល

៤. ផលិតផលគំរូ។

**ប្រការ៧ ..**

លក្ខខណ្ឌនៃទំនិញវេចខ្ចប់ ដែលត្រូវអនុញ្ញាតឱ្យនាំចូលគឺ៖

១. ត្រូវបញ្ជាក់អំពីបរិមាណសុទ្ធ និងធានាភាពត្រឹមត្រូវនៃទម្ងន់ និងរង្វាស់រង្វាល់ នៅលើសម្ភារៈវេចខ្ចប់ទំនិញនោះ

២. ត្រូវគោរពតាមប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ដូចមានបញ្ជាក់ក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា

៣. ត្រូវធ្វើ ឬរៀបចំឡើងតាមការបញ្ជាក់ជាលក្ខណៈដើមនៃគំរូដែលបានអនុម័តពីទម្ងន់ ឬរង្វាស់រង្វាល់

៤. ត្រូវបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកផលិត ឬ អ្នកវេចខ្ចប់ ឬ ពាណិជ្ជសញ្ញាដើម្បីធានាភាពច្បាស់លាស់

៥. ត្រូវអនុលោមតាមប្រកាសលេខ ២៧៤ MISTI/២០២០ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ ស្តីពីបទប្បញ្ញត្តិបច្ចេកទេសនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់បរិមាណ និងស្លាកសញ្ញាទំនិញផលិត និងទំនិញវេចខ្ចប់។

**ប្រការ៨ ..**

ក្រោយពីមន្ត្រីត្រួតពិនិត្យនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ បានពិនិត្យវាយតម្លៃលើពាក្យស្នើសុំ និងធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ទំនិញវេចខ្ចប់គំរូ តាមបែបបទ និងនីតិវិធីដូចមានចែងក្នុងប្រការ៦ និងប្រការ៧នៃប្រកាសនេះរួចរាល់ហើយ ក្រសួងត្រូវឆ្លើយតបអំពីការសម្រេចរបស់ខ្លួនទៅអ្នកស្នើសុំក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃយ៉ាងយូរនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃដែលទទួលបានពាក្យស្នើសុំ ក្នុងករណីមិនយល់ព្រមតាមការស្នើសុំ ក្រសួងត្រូវឆ្លើយតបទៅអ្នកស្នើសុំដោយបញ្ជាក់ពីមូលហេតុឱ្យបានត្រឹមត្រូវ។ វិញ្ញាបនបត្របញ្ជាក់លក្ខណៈមាត្រាសាស្ត្រលើទំនិញវេចខ្ចប់នាំចូលនេះ មានសុពលភាព ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ប្រការ៩ ..**

រាល់ការផ្ទេរ ការលក់នូវវិញ្ញាបនបត្របញ្ជាក់លក្ខណៈមាត្រាសាស្ត្រលើទំនិញវេចខ្ចប់នាំចូល ត្រូវមានការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ១០ ..**

នៅពេលទំនិញវេចខ្ចប់ បាននាំចូលមកដល់ព្រះរាជាណាចក្រកម្ពុជា អ្នកនាំចូលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មកមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីស្នើសុំមន្ត្រីត្រួតពិនិត្យ ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ផលិតផលជាក់ស្តែង។

**ប្រការ១១ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១២ ..**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល គ្រប់អង្គភាពក្រោមឱវាទក្រសួង និងរូបវន្តបុគ្គល នីតិបុគ្គលដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៥កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០២២

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា**

**និងនវានុវត្តន៍**

***កិត្តិសេដ្ឋាបណ្ឌិត* ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១២
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com